កុំព្យូទ័រ [redacted] (10:24:30) / ធំទំ 1

ព 10. 6. 2014

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១០៧២/១១-១២-២០១៣
សាលដីកា
លេខ ២៩ ក្រ$_{III}$"ណ"/០៥-៥-១៤

# គាមនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ២២-៤-២០១៤ (៨$^{ម}$០០) ដែលមានសមាសភាពដូចខាងក្រោម ៖

<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ជាព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១០៧២ ចុះថ្ងៃទី ១១-១២-២០១៣ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

**-ជនជាប់ចោទឈ្មោះ** [redacted] ហៅ ពេជ្រ ហៅ ទុំ ភេទប្រុស អាយុ ២២ ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅសង្កាត់អូរឫស្សី ៣ ខណ្ឌ៧មករា រាជធានីភ្នំពេញ ទីលំនៅមុនពេល [redacted] ផ្លូវលេខ ១៦៦ សង្កាត់អូរឫស្សី ៣ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ "**ក្នុងឃុំ**" (**ប្តឹងឧទ្ធរណ៍**) ។

ឃុំខ្លួននៅពន្ធនាគារព្រៃស (ម$_{១}$) តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥៨៧ តព្រ ចុះថ្ងៃទី ១៤-៩-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

មានលោក [redacted] អ៊ូង ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

<u>ជាប់ចោទពីបទៈ</u> **អំពើលួចមានស្ថានទម្ងន់ទោស និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តិនៅចំណុចផ្លូវលេខ ១៥៣ កែងផ្លូវលេខ ៣០០ ក្រុម ៣៩ ភូមិ ៥ សង្កាត់អូរឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលថ្ងៃទី ១៦-៧-១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រតនា (ជនរងគ្រោះ) ភេទប្រុស អាយុ ១៩ ឆ្នាំ ជាតិខ្មែរ មុខរបរជាងជួសជុលទូរស័ព្ទដៃ ទីលំនៅសព្វថ្ងៃនៅភូមិព្រៃមាស ឃុំនគររាជ្យ ស្រុកព្រះស្តេច ខេត្តព្រៃវែង ។

<u>ឯរឿងហេតុមានដូចតទៅ</u>

**សកម្មភាព**ប្រព្រឹត្តរបស់ជនជាប់ចោទមានដូចខាងក្រោម៖

កាលពីថ្ងៃទី **១៦-៧-២០១២** វេលាម៉ោង **២:០០** នាទី រំលងអាធ្រាត្រ ជនរងគ្រោះឈ្មោះ [redacted] **រតនា** ជិះម៉ូតូមួយគ្រឿងម៉ាកស្កុបពី ពណ៌ក្រហម សេរីឆ្នាំ **២០១២** ពាក់ស្លាកលេខ **ភ្នំពេញ 1 BG-6420** ចេញពីផ្ទះសំណាក់សំណាងល្អជាមួយសន្តិសុខយាមផ្ទះសំណាក់ឈ្មោះ **សារ៉ាន** ទៅទិញទឹកក្រឡុក ពេលត្រឡប់មកវិញដល់ចំណុចផ្លូវលេខ ១៥៣ កែងផ្លូវលេខ ៣០០ ក្រុម ៣៩ ភូមិ ៥ សង្កាត់អូរឡាំពិក ខណ្ឌចំការមន ស្រាប់តែមានជនសង្ស័យចំនួន **០៥** នាក់ គឺ៖

១-ឈ្មោះ [redacted] **លីណោង** ហៅ ពេជ្រ ហៅ រុំ,

២-ឈ្មោះ [redacted] **ជីវ័ន្ត** ហៅ **អាបាយជ្រូក**,

៣-ឈ្មោះ [redacted] **ឧត្តម** ហៅ **សៅ**,

៤-ឈ្មោះ [redacted] ដុល្លា ហៅ តុលា,

៥-ឈ្មោះ **ហាប់**

ជិះម៉ូតូ **០២** គ្រឿង មានម៉ាកហុងដាអែវប្លែក ពណ៌ខ្មៅ **០១** គ្រឿង មានជនសង្ស័យឈ្មោះ [redacted] ដុល្លា ហៅ តុលា ជាអ្នកឌុបឈ្មោះ [redacted] **ឧត្តម** ហៅ **សៅ** ចំណែកឈ្មោះ [redacted] **លីណោង** ហៅ ពេជ្រ ហៅ រុំ ជាអ្នកធ្វើសកម្មភាពដកកាំភ្លើងភ្ជង់ជនរងគ្រោះយកម៉ូតូម៉ាកស្កុបពី ពណ៌ក្រហម សេរីឆ្នាំ **២០១២** ពាក់ស្លាកលេខ **ភ្នំពេញ 1 BG-6420** និងមានម៉ូតូម៉ាកហុងដាសេ **១២៥** ពណ៌ខ្មៅ ពាក់ស្លាកលេខ **ភ្នំពេញ 1 BH-5600** មួយគ្រឿងទៀត ជិះដោយឈ្មោះ [redacted] **ជីវ័ន្ត** ហៅ **អាបាយជ្រូក** ឌុបឈ្មោះ **ហាប់** ជិះបិទគូទពីក្រោយគេចខ្លួនបាត់ ហើយបន្ទាប់មកក៏យកម៉ូតូទៅលក់ឲ្យឈ្មោះ **ដុង** បានប្រាក់ចំនួន **៧៥០ ដុល្លារអាមេរិក** ចែកគ្នាបានម្នាក់ **១៥០ ដុល្លារអាមេរិក** ចំណែកឈ្មោះ [redacted] **ជីវ័ន្ត** ហៅ **អាបាយជ្រូក** បានប្រាក់តែ **១០០ ដុល្លារអាមេរិក** ប៉ុណ្ណោះទេ ។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ **៦៤ "កប៣" ណ** ចុះថ្ងៃទី **០៥-៨-២០១៣** របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

**១-ផ្តន្ទាទោស៖**

ក/ឈ្មោះ [redacted] **ឧត្តម** ហៅ **សៅ** ភេទប្រុស អាយុ ២០ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន **០៣ "បី" ឆ្នាំ** ។

ខ/ឈ្មោះ [redacted] **លីណោង** ហៅ ពេជ្រ ហៅ រុំ ភេទប្រុស អាយុ ២២ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន **០៣ "បី" ឆ្នាំ** ។

គ/ឈ្មោះ [redacted] **ដុល្លា** ហៅ តុលា ភេទប្រុស អាយុ ២១ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន **០៣ "បី" ឆ្នាំ** ។

<u>ពីបទ</u>៖ **លួចមានស្ថានទម្ងន់ទោស និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តិនៅចំណុចផ្លូវលេខ ១៥៣ កែងផ្លូវលេខ ៣០០ ក្រុម ៣៩ ភូមិ ៥ សង្កាត់អូរឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី **១៦-៧-១២** តាមបញ្ញត្តិមាត្រា **៣៥៣**, មាត្រា **៣៥៧** និងមាត្រា **៤៩០** នៃក្រមព្រហ្មទណ្ឌ ។

**២-ផ្តន្ទាទោស៖**

ក/ឈ្មោះ [redacted] **ជីវ័ន្ត** ហៅ **អាបាយជ្រូក** ភេទប្រុស អាយុ២០ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន **០៣ "បី" ឆ្នាំ** ។

ខ/ឈ្មោះ [redacted] **ពេជ្ជ** ភេទប្រុស អាយុ ២៥ ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន **០៣ "បី" ឆ្នាំ** ។

<u>ពីបទ</u>៖ **សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស និងកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត** ប្រព្រឹត្តិនៅចំណុចផ្លូវលេខ ១៥៣ កែងផ្លូវលេខ ៣០០ ក្រុម៣៩ ភូមិ ៥ សង្កាត់អូរឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី **១៦-៧-២០១២** តាមបញ្ញត្តិមាត្រា **២៩**, មាត្រា **៣៥៣**, មាត្រា **៣៥៧** និងមាត្រា **៤៩០** នៃក្រមព្រហ្មទណ្ឌ

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី **១៦-៧-២០១៣** ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ឧត្តម**, ឈ្មោះ [redacted] **ដុល្លា**, ឈ្មោះ [redacted] **លីណោង**, ឈ្មោះ [redacted] **ជីវ័ន្ត** កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **ពេជ្ជ** ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី **០៥-៨-២០១៣** ។

បើកផ្លូវប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍លេខ **៥៩៩** ចុះថ្ងៃទី **២៧-៨-២០១៣** របស់ជនជាប់ចោទឈ្មោះ [redacted] **លីណោង** ប្តឹងឧទ្ធរណ៍និងសាលក្រមព្រហ្មទណ្ឌលេខ **៦៤ "កប៣" ណ** ចុះថ្ងៃទី **០៥-៨-២០១៣** របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**បានឃើញ**របាយការណ៍រឿង ចុះថ្ងៃទី**០៥-០២-២០១៤** របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

**បានឃើញ**សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី **០៧-៣-២០១៤** របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] **លីណោង** ឆ្លើយថា ខ្លួនមិនបានធ្វើសកម្មភាពជាមួយពួកគេទេ ខ្លួនគ្រាន់តែទៅជាមួយពួកគេប៉ុណ្ណោះ ហើយខ្លួនមិនបានដឹងពីគំនិតរបស់ពួកគេដែលចង់ធ្វើអំពើល្មើសច្បាប់នោះឡើយ ។ ខ្លួនបានទទួលប្រាក់ពីពួកគេចំនួន **១៥០ ដុល្លារ** ។ ចំពោះកាំភ្លើងជារបស់ឈ្មោះ **ឧត្តម** តែនៅមុនពេលកើតហេតុនោះ ខ្លួនមិនបានដឹងថា ឈ្មោះ **ឧត្តម** មានកាំភ្លើងទេ តែខ្លួនគ្មានភស្តុតាងអ្វីបញ្ជាក់ជូនតុលាការឡើយ ។ ចំពោះមិត្តភ័ក្រទាំងអស់នោះ ខ្លួនស្គាល់តែឈ្មោះ **តុលា** ម្នាក់ប៉ុណ្ណោះ ។ ខ្លួនមិនដែលឃើញពួកគេមានកាំភ្លើងទេ នៅមុនពេលដែលពួកគេធ្វើសកម្មភាពនោះ ។ ចំពោះចម្លើយដែលខ្លួនឆ្លើយនៅសមត្ថកិច្ចនោះ គឺគេវាយបង្ខំឲ្យឆ្លើយ ។

ឈ្មោះ **ឧត្តម** ជាអ្នកមានកាំភ្លើង និងជាអ្នកភ្ជង់ជនរងគ្រោះ តែមិនបានបាញ់ទេ ។ ខ្លួនប្តឹងឧទ្ធរណ៍មកដើម្បីសុំឲ្យតុលាការបន្ថយទោសមកនៅត្រឹម **០២ ឆ្នាំ** ។

-ក្រឡាបញ្ជីអានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **លីណោង** ឆ្លើយនៅសមត្ថកិច្ច ។

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា អង្គហេតុនៃរឿងនេះ មិនមានលក្ខណៈប្រែប្រួលទេ គឺដូចរបាយការណ៍របស់ចៅក្រម ដែលលោកប្រធានក្រុមប្រឹក្សាអានសង្ខេបនេះ ហើយការសម្រេចសេចក្តីរបស់សាលាដំបូង មានលក្ខណៈសមស្របដែរ ហេតុដូច្នេះ សុំឲ្យក្រុមប្រឹក្សាជំនុំជម្រះតម្កល់សាលក្រម ទុកជាបានការ ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានឆ្លើយបញ្ជាក់ហើយថា មិនបានចូលរួមធ្វើសកម្មភាពជាមួយពួកគេទេ គឺគ្រាន់តែបានធ្វើដំណើរជាមួយពួកគេប៉ុណ្ណោះ ចំពោះចម្លើយនៅសមត្ថកិច្ច ជាចម្លើយដែលបង្ខំឲ្យឆ្លើយ ។ ផ្អែកតាមមាត្រា **៣៨** កថាខណ្ឌទី **៥** នៃរដ្ឋធម្មនុញ្ញ និងមាត្រា **៣២១** នៃក្រមនីតិវិធីព្រហ្មទណ្ឌ សុំឲ្យក្រុមប្រឹក្សាមេត្តាពិចារណាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនមកត្រឹម **០២ ឆ្នាំ** ដើម្បីឆាប់បានចេញមកមើលថែទាំម្តាយចាស់ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>សាលាឧទ្ធរណ៍យល់ឃើញថា</u>

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ **៥៩៩** ចុះថ្ងៃទី **២៧-៨-២០១៣** របស់ជនជាប់ចោទឈ្មោះ [redacted] **លីណោង** ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ **៦៩ "កបព" ណ** ចុះថ្ងៃទី **០៥-៨-១៣** របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា **៣៧៣**, មាត្រា **៣៧៥**, មាត្រា **៣៧៦** និងមាត្រា **៣៨២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអាចឲ្យសាលាឧទ្ធរណ៍ទទួលយកសំណុំរឿងព្រហ្មទណ្ឌលេខ **១០៧២** ចុះថ្ងៃទី **១១-១២-២០១៣** របស់សាលាឧទ្ធរណ៍ មកធ្វើការជំនុំជម្រះបាន ។

២-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] **លីណោង** ឆ្លើយថា ខ្លួនបានប្តឹងឧទ្ធរណ៍ចំពោះសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ គឺចង់សុំឲ្យបន្ធូរបន្ថយទោស ។ ពេលបក្សពួកខ្លួនធ្វើសកម្មភាព ខ្លួនក៏នៅកន្លែងកើតហេតុដែរ ហើយចំពោះចម្លើយដែលខ្លួនបានឆ្លើយនៅមុខសមត្ថកិច្ច គឺជាចម្លើយបង្ខិតបង្ខំ ។

៣-ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទ និងការពិនិត្យភស្តុតាងក្នុងសំណុំរឿងឃើញថា សំអាងហេតុ និងសេចក្តីសម្រេចក្នុងសាលក្រមព្រហ្មទណ្ឌលេខ **៦៩ "កបព" ណ** ចុះថ្ងៃ **០៥-៨-២០១៣** របស់សាលាដំបូងរាជធានីភ្នំពេញ មានមូលហេតុត្រឹមត្រូវ គប្បីសាលាឧទ្ធរណ៍ចេញសាលដីកាតម្កល់សាលក្រមនេះ ទុកជាបានការ លើកលែងតែទណ្ឌកម្មដែលផ្តន្ទាទោសលើជនជាប់ចោទ ត្រូវតែប្រែ ព្រោះថា ជនជាប់ចោទបានសារភាព មានគំនិតភ្ញាក់រលឹក ហើយសន្យា

ថា នឹងកែប្រែខ្លួនជាពលរដ្ឋល្អ និងពុំដែលមានការផ្តន្ទាទោសណាមួយពីមុនមក ដែលគប្បីសាលាឧទ្ធរណ៍ លើកយកការប្រកាសទោសព្យួរ មកពិចារណាចំពោះទណ្ឌកម្ម ដែលបានប្រកាសដល់ជនជាប់ចោទ ។

៤-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទបានសារភាព ដូច្នេះ អង្គហេតុក្នុងរឿងក្តីពុំមានលក្ខណៈប្រែប្រួល ហេតុដូច្នេះ សុំឲ្យក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៥-មេធាវីការពារសិទ្ធិជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា ចម្លើយរបស់កូនក្តីខ្លួនដែលបានឆ្លើយនៅមុខសមត្ថកិច្ច គឺជាចម្លើយដោយបង្ខិតបង្ខំ ដូច្នេះ សុំឲ្យក្រុមប្រឹក្សាផ្តន្ទាទោសកូនក្តីខ្លួនត្រឹមតែ ០២ ឆ្នាំ ។

៦-ជនជាប់ចោទនិយាយសំដីចុងក្រោយថា សុំឲ្យក្រុមប្រឹក្សាជួយបន្ធូរបន្ថយទោស ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៥៩៩ ចុះថ្ងៃទី២៧-៨-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] លីណោង ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៩"កប៣" ណ ចុះថ្ងៃទី ០៥-៨-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែទណ្ឌកម្មដែលផ្តន្ទាទោសលើជនជាប់ចោទត្រូវកែប្រែពីផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ០៣ (បី) ឆ្នាំ មកជាផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ០៣ (បី) ឆ្នាំ ទោសអនុវត្តក្នុងពន្ធនាគាររយៈពេល ០២ (ពីរ) ឆ្នាំ ទោសដែលនៅសល់ត្រូវព្យួរតាមមាត្រា ១០៦, មាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៤-សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី ២២-៤-២០១៤ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៥-៥-២០១៤ ទុកសិទ្ធិឲ្យប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

ភ្នំពេញ ថ្ងៃទី 10 ខែ 6 ឆ្នាំ ២០១៤

ប្រធានសាលាឧទ្ធរណ៍

ក្រឡាបញ្ជី

[redacted]